ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រុមប្រឹក្សាអាជ្ញាកណ្ដាល
THE ARBITRATION COUNCIL

លេខ និង ឈ្មោះសំណុំរឿង ៖ ០០៤/១៩ - អេវើប្រ៊ីន អឺភែរឹល (ខេមបូឌា)
កាលបរិច្ឆេទនៃសេចក្ដីបង្គាប់ ៖ ថ្ងៃទី០៥ ខែកុម្ភៈ ឆ្នាំ២០១៩

# សេចក្ដីបង្គាប់អាជ្ញាកណ្ដាល

(ធ្វើឡើងស្របតាមមាត្រា ៣១៣ នៃច្បាប់ស្ដីពីការងារ)

## សមាសភាពក្រុមអាជ្ញាកណ្ដាល

អាជ្ញាកណ្ដាលជ្រើសរើសឡើងដោយភាគីនិយោជក ៖ អ៊ឹង សុទ្ធី
អាជ្ញាកណ្ដាលជ្រើសរើសឡើងដោយភាគីកម្មករនិយោជិត ៖ លីវ សុវណ្ណា
ប្រធានក្រុមអាជ្ញាកណ្ដាលជ្រើសរើសឡើងដោយអាជ្ញាកណ្ដាលទាំងពីរខាងលើ ៖ ប៉ែន ប៊ុនឈា

## ភាគីនៃវិវាទ

### ១- ភាគីនិយោជក

ឈ្មោះ ៖ **ក្រុមហ៊ុន អេវើប្រ៊ីន អឺភែរឹល (ខេមបូឌា)**
អាសយដ្ឋាន ៖ ភូមិចុងថ្នល់ខាងកើត សង្កាត់ទឹកថ្លា ខណ្ឌសែនសុខ រាជធានីភ្នំពេញ
ទូរស័ព្ទ ៖ ០១៦ ៨៨៨ ៣៨៨     ទូរសារ ៖ គ្មាន
តំណាងភាគីនិយោជកចូលរួមសវនាការ៖ អវត្តមាន

### ២- ភាគីកម្មករនិយោជិត

ឈ្មោះ ៖ **ភាគីតំណាងកម្មករនិយោជិតក្នុងការដោះស្រាយវិវាទការងាររួម នៃក្រុមហ៊ុន អេវើប្រ៊ីន អឺភែរឹល (ខេមបូឌា)**
អាសយដ្ឋាន ៖ ភូមិចុងថ្នល់ខាងកើត សង្កាត់ទឹកថ្លា ខណ្ឌសែនសុខ រាជធានីភ្នំពេញ
ទូរស័ព្ទ ៖ ០១២ ៨៨ ០០ ៣៩     ទូរសារ ៖ គ្មាន
តំណាងភាគីកម្មករនិយោជិតចូលរួមសវនាការ៖

| | |
|---|---|
| ១- លោកស្រី យ៉ាង សុភ័ណ្ឌ | ប្រធានសហព័ន្ធសហជីពកម្ពុជា |
| ២- លោកស្រី ប៊ុន ផល្លា | កម្មករ |
| ៣- កញ្ញា យ៉ន យ៉ឺន | កម្មករ |
| ៤- លោកស្រី ជី ចាន់ធឿន | កម្មករ |

៥- លោកស្រី ស៊ន់ ណៃយ៉ុន កម្មករ

៦- លោកស្រី ហេង សុភ័ក្រ កម្មករ

៧- លោកស្រី ហួន អេង កម្មករ

៨- កញ្ញា ធុច យីន កម្មករ

៩- លោកស្រី ចែម ស្រីនី កម្មករ

១០- លោកស្រី ហាម ថារី កម្មករ

១១- លោកស្រី ញាញ គឿន កម្មករ

**បញ្ហាក្នុងវិវាទ**

(នៅក្នុងរបាយការណ៍ផ្សះផ្សាមិនសះជា)

១- ស្នើសុំឱ្យក្រុមហ៊ុនឈប់ព្យួរការងារខុសនីតិវិធីច្បាប់។

២- ស្នើសុំឱ្យក្រុមហ៊ុនសងលុយត្រឡប់មកកម្មករនិយោជិតវិញ ពេលព្យួរការងារមិនត្រឹមត្រូវកន្លងមក (ថ្ងៃទី១៨-២១ និងថ្ងៃទី២៨-២៩ ខែធ្នូ ឆ្នាំ២០១៨)។

៣- ស្នើសុំឱ្យក្រុមហ៊ុនផ្តល់ការងារឱ្យកម្មករនិយោជិតធ្វើឱ្យបានគ្រប់គ្រាន់។

**អំណាចយុត្តាធិការរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាល**

ក្រុមប្រឹក្សាអាជ្ញាកណ្តាលទទួលអំណាចក្នុងការចេញសេចក្តីបង្គាប់នេះ ដោយយោងតាមជំពូកទី១២ ផ្នែកទីពីរ (ខ) (មាត្រា ៣០៩ ដល់ ៣១៧) នៃច្បាប់ស្តីពីការងារឆ្នាំ១៩៩៧ ប្រកាសស្តីពីក្រុមប្រឹក្សាអាជ្ញាកណ្តាលលេខ ០៩៩ សកបយ ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៤ វិធាននៃនីតិវិធីក្រុមប្រឹក្សាអាជ្ញាកណ្តាល ដែលភ្ជាប់ជាឧបសម្ព័ន្ធនៃប្រកាសលេខ ០៩៩ សកបយ ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៤ និងប្រកាសស្តីពីការតែងតាំងសមាជិកក្រុមប្រឹក្សាអាជ្ញាកណ្តាលលេខ ២២០ ក.ប/ប្រ.ក.វ.ក ចុះថ្ងៃទី២៣ ខែឧសភា ឆ្នាំ២០១៨ (អាណត្តិទី១៦)។

ការព្យាយាមផ្សះផ្សាវិវាទការងាររួម ដែលជាកម្មវត្ថុនៃសេចក្តីបង្គាប់នេះ ត្រូវបានធ្វើឡើងស្របតាមជំពូកទី១២ ផ្នែកទី២ (ក) នៃច្បាប់ស្តីពីការងារ។ ប៉ុន្តែ ការផ្សះផ្សានោះ ភាគីទាំងពីរមិនបានឯកភាពសះជានឹងគ្នាឡើយ ហើយរបាយការណ៍ស្តីអំពីការដោះស្រាយវិវាទការងាររួមនៃក្រុមហ៊ុន អេវើហ្គ្រីន អ៊ីភែរីល (ខេមបូឌា) លេខ ០៣៥ ក.ប/អក/វក ចុះថ្ងៃទី១១ ខែមករា ឆ្នាំ២០១៩ ត្រូវបានបញ្ជូនមកលេខាធិការដ្ឋាននៃក្រុមប្រឹក្សាអាជ្ញាកណ្តាល នៅថ្ងៃទី១៤ ខែមករា ឆ្នាំ២០១៩។

**សវនាការ និង សង្ខេបនីតិវិធី**

**ទីកន្លែងសវនាការ ៖** ក្រុមប្រឹក្សាអាជ្ញាកណ្តាល ភូមិគ្រឹះលេខ ៧២ ផ្លូវលេខ ៥៩២ កាច់ជ្រុងផ្លូវលេខ ញូញ៉ា (ទល់មុខវិទ្យាល័យឥន្ទ្រទេវី), សង្កាត់បឹងកក់ ២, ខណ្ឌទួលគោក, រាជធានីភ្នំពេញ។

**កាលបរិច្ឆេទសវនាការ ៖** ថ្ងៃអង្គារ ២រោច ខែបុស្ស ឆ្នាំច សំរឹទ្ធិស័ក ព.ស ២៥៦២ ត្រូវនឹងថ្ងៃទី២២ ខែមករា ឆ្នាំ២០១៩ វេលាម៉ោង ១៤ និង ០០ នាទី រសៀល។

**បញ្ហានីតិវិធី៖**

នៅថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០១៨ នាយកដ្ឋានវិវាទការងារ បានទទួលពាក្យបណ្តឹងរបស់កម្មករនិយោជិត នៃក្រុមហ៊ុន អេវើហ្គ្រីន អ៊ីភែរីល (ខេមបូឌា) ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០១៨ ស្តីពីទាមទារសុំឱ្យក្រុមហ៊ុន អេវើហ្គ្រីន អ៊ីភែរីល (ខេមបូឌា) ដោះស្រាយលក្ខខណ្ឌការងារ ចំនួន ៣ ចំណុច ឱ្យបានល្អប្រសើរ។ បន្ទាប់ពីទទួលពាក្យបណ្តឹងនេះមក នាយកដ្ឋានវិវាទការងារ បានចាត់មន្ត្រីជំនាញឱ្យធ្វើការដោះស្រាយវិវាទការងារនេះជាបន្តបន្ទាប់ និងធ្វើការផ្សះផ្សានៅថ្ងៃទី១០ ខែមករា ឆ្នាំ២០១៩ ដោយមិនទទួលបានលទ្ធផលសះជានឹងគ្នាទេ លើការទាមទារ ចំនួន ៣ ចំណុច។ ចំណុចមិនសះជាដែលនៅសល់ទាំង ៣ ចំណុចនេះ ត្រូវបានបញ្ជូនមកលេខាធិការដ្ឋាននៃក្រុមប្រឹក្សាអាជ្ញាកណ្តាល នៅថ្ងៃទី១៤ ខែមករា ឆ្នាំ២០១៧ តាមរបាយការណ៍ស្តីពីការដោះស្រាយវិវាទការងាររួម នៃក្រុមហ៊ុន អេវើហ្គ្រីន អ៊ីភែរីល (ខេមបូឌា) លេខ ០០៤ ក.ប/អក/វក ចុះថ្ងៃទី ១៤ ខែមករា ឆ្នាំ២០១៧។

បន្ទាប់ពីបានទទួលសំណុំរឿងនេះ លេខាធិការដ្ឋាននៃក្រុមប្រឹក្សាអាជ្ញាកណ្តាល មិនអាចទំនាក់ទំនងភាគីនិយោជក ដើម្បីធ្វើការជ្រើសរើសអាជ្ញាកណ្តាលបានទេ។ ដូច្នេះ មន្ត្រីលេខាធិការដ្ឋាននៃក្រុមប្រឹក្សាអាជ្ញាកណ្តាល បានទៅកាន់ទីតាំងក្រុមហ៊ុនផ្ទាល់ ដើម្បីយកលិខិតអញ្ជើញភាគីនិយោជកធ្វើការជ្រើសរើសអាជ្ញាកណ្តាល លេខ ០៣៨ កប/អក/វក/លកអ. ចុះថ្ងៃទី១៤ ខែមករា ឆ្នាំ២០១៩ បិទផ្សាយលិខិតអញ្ជើញជ្រើសរើសអាជ្ញាកណ្តាល នៅរោងចក្រ អេវើហ្គ្រីន អ៊ីភែរីល (ខេមបូឌា)។ នៅថ្ងៃទី១៦ ខែមករា ឆ្នាំ២០១៩ លេខាធិការដ្ឋាននៃក្រុមប្រឹក្សាអាជ្ញាកណ្តាលបានអនុវត្តនីតិវិធីជ្រើសរើសអាជ្ញាកណ្តាលនិយោជកតាមការចាប់ឆ្នោត ដូចមានចែងក្នុងប្រការ ១៣ នៃប្រកាស ០៩៩ ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៤ ស្តីពីក្រុមប្រឹក្សាអាជ្ញាកណ្តាល និងវិធាន ៣.១ នៃនីតិវិធីក្រុមប្រឹក្សាអាជ្ញាកណ្តាល។

ក្រុមអាជ្ញាកណ្តាលត្រូវបានបង្កើតឡើង នៅថ្ងៃទី១៦ ខែមករា ឆ្នាំ២០១៩។ លេខាធិការដ្ឋាននៃក្រុមប្រឹក្សាអាជ្ញាកណ្តាល បានធ្វើការកោះអញ្ជើញភាគីនិយោជក និងភាគីកម្មករនិយោជិត មកសវនាការ និងធ្វើការផ្សះផ្សាលើករណីមិនសះជាទាំង ៣ ចំណុច នៅថ្ងៃទី២២ ខែមករា ឆ្នាំ២០១៩ វេលាម៉ោង ១៤ និង ០០ នាទី រសៀល។ ភាគីកម្មករនិយោជិត មានវត្តមាននៅក្នុងសវនាការតាមការអញ្ជើញរបស់លេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល។

ដោយមិនអាចធ្វើការទំនាក់ទំនងទៅភាគីនិយោជកបាន និងដោយហេតុថា ក្រុមហ៊ុន អេវើហ្គ្រីន អ៊ីភែរីល (ខេមបូឌា) ជាសមាជិកនៃសមាគមន៍រោងចក្រកាត់ដេរនៅកម្ពុជា នៅថ្ងៃទី១៦ ខែមករា ឆ្នាំ២០១៩ វេលាម៉ោង ១១ និង ២០ នាទី ព្រឹក មន្ត្រីលេខាធិការដ្ឋាននៃក្រុមប្រឹក្សាអាជ្ញាកណ្តាល បានធ្វើការទាក់ទងទៅកាន់លោក សួង ហួត ដែលជាមន្ត្រីនៃសមាគមន៍រោងចក្រកាត់ដេរនៅកម្ពុជា ហៅកាត់ថា GMAC ដើម្បីជូនដំណឹងស្តីពីកាលបរិច្ឆេទសវនាការដល់ភាគីនិយោជក។ លេខាធិការដ្ឋាននៃក្រុមប្រឹក្សាអាជ្ញាកណ្តាល បានជម្រាបទៅកាន់លោក សួង ហួត ដោយបញ្ជាក់ពីព័ត៌មាន នៃលិខិតអញ្ជើញចូលរួមសវនាការក្រុមប្រឹក្សាអាជ្ញាកណ្តាល លេខ ០៤១ កប/អក/វក/លកអ. ចុះថ្ងៃទី១៦ ខែមករា ឆ្នាំ២០១៩ ដែលមានភ្ជាប់ជាមួយនូវព័ត៌មានច្បាស់លាស់ អំពីកាលបរិច្ឆេទនៃសវនាការ នាថ្ងៃទី២២ ខែមករា ឆ្នាំ២០១៩ វេលាម៉ោង ១៤ និង ០០ នាទី រសៀល ទីកន្លែងនៃសវនាការ ព្រមទាំងលេខទូរស័ព្ទ/ទូរសារ សម្រាប់ទំនាក់ទំនងមកក្រុមប្រឹក្សាអាជ្ញាកណ្តាលផងដែរ។

ARBITRATION COUNCIL

ដោយឡែក ភាគីនិយោជកមិនមានវត្តមាននៅក្នុងសវនាការរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាល តាមការអញ្ជើញនោះទេ ប៉ុន្តែមានវត្តមានលោក សួង ហួត ដែលជាមន្ត្រីនៃសមាគមន៍រោងចក្រកាត់ដេរនៅកម្ពុជា ដោយបានបញ្ជាក់ថា ថៅកែក្រុមហ៊ុន មិនមានវត្តមាននៅក្នុងប្រទេសកម្ពុជាទេ ដោយគាត់បានត្រឡប់នៅប្រទេសកំណើតរបស់គាត់វិញ ដើម្បីចូលរួមពិធីបុណ្យសពរបស់ឪពុកគាត់។ ម៉្យាងវិញទៀត ថៅកែក្រុមហ៊ុនក៏មិនមានធ្វើលិខិតផ្ទេរសិទ្ធិឱ្យលោក សួង ហួត ដើម្បីធ្វើជាតំណាងក្នុងការដោះស្រាយវិវាទការងារក្នុងសំណុំរឿងនេះទេ ហើយវត្តមានរបស់លោក នៅថ្ងៃសវនាការនេះ គឺដើម្បីពាំនាំនៅជំហររបស់និយោជក ក្នុងការផ្តល់ប្រាក់បំណាច់ផ្តាច់កិច្ចសន្យាការងាររបស់កម្មករនិយោជិត តែប៉ុណ្ណោះ។

នៅថ្ងៃសវនាការ ក្រុមប្រឹក្សាអាជ្ញាកណ្តាលបានព្យាយាមសួររកនូវអង្គហេតុផ្សេងៗ ដែលទាក់ទងទៅនឹងចំណុចវិវាទដែលនៅសល់ទាំង ៣ ចំណុចនេះ បន្ថែមទៀត ដោយកម្មករនិយោជិតសម្រេចបញ្ចូលចំណុចវិវាទទី១ ទី២ និងទី៣ ទៅជាមួយចំណុចវិវាទតែមួយ។ ដូចនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលនឹងធ្វើការពិចារណាទៅលើចំណុចវិវាទចំនួន ១ ចំណុច ប៉ុណ្ណោះ។

នៅក្នុងសំណុំរឿងនេះ ប្រភេទសេចក្តីបង្គាប់អាជ្ញាកណ្តាលគឺជាសេចក្តីបង្គាប់មិនជាប់កាតព្វកិច្ច។

នៅថ្ងៃសវនាការ ក្រុមប្រឹក្សាអាជ្ញាកណ្តាលបានកំណត់ថ្ងៃទី២៣ ខែមករា ឆ្នាំ២០១៩ ជាថ្ងៃផុតកំណត់ផ្តល់ឯកសារ និងថ្ងៃទី២៥ ខែមករា ឆ្នាំ២០១៩ ជាថ្ងៃផុតកំណត់ជំទាស់ឯកសារ។

កាលបរិច្ឆេទនៃការចេញសេចក្តីបង្គាប់អាជ្ញាកណ្តាល គឺនៅថ្ងៃទី៥ ខែកុម្ភៈ ឆ្នាំ២០១៩។

ដូច្នេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលធ្វើការពិចារណា និងដោះស្រាយលើចំណុចវិវាទខាងលើនេះ ដោយផ្អែកលើភស្តុតាង និងការរកឃើញនៃអង្គហេតុ ដូចខាងក្រោម ៖

**ភស្តុតាង**

សាក្សី និង អ្នកជំនាញក្រៅពីភាគី ៖ គ្មាន

**ឯកសារ ភស្តុតាង ដែលក្រុមអាជ្ញាកណ្តាលយកមកពិចារណាមាន**

**ក- ឯកសារបានទទួលពីភាគីនិយោជក** ៖ គ្មាន

**ខ- ឯកសារបានទទួលពីភាគីកម្មករនិយោជិត** ៖

១- លិខិតចុះថ្ងៃទី២៤ ខែមករា ឆ្នាំ២០១៩ គោរពជូន លេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល ស្តីពីសំណើដាក់ជូនបញ្ជីឈ្មោះកម្មករនិយោជិតរោងចក្រ អេវើហ្គ្រីន អ៊ីភែរីល (ខេមបូឌា)។

២- កាតសម្គាល់ខ្លួនកម្មករនិយោជិតក្រុមហ៊ុន អេវើហ្គ្រីន អ៊ីភែរីល (ខេមបូឌា)។

**គ- ឯកសារបានទទួលពីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

១- របាយការណ៍ស្តីពីការដោះស្រាយវិវាទការងាររួមនៅក្រុមហ៊ុន អេវើហ្គ្រីន អ៊ីភែរីល (ខេមបូឌា) លេខ ០៣៥ ក.ប/អក/វក ចុះថ្ងៃទី១១ ខែមករា ឆ្នាំ២០១៩។

២- កំណត់ហេតុនៃការផ្សះផ្សាវិវាទការងាររួមនៅក្រុមហ៊ុន អេវើហ្រ្គីន អីភែរីល (ខេមបូឌា) ចុះថ្ងៃទី១០ ខែមករា ឆ្នាំ២០១៩។

៣- លិខិតបញ្ជាក់អ្នកតំណាងភាគីកម្មករនិយោជិតក្នុងការដោះស្រាយវិវាទការងាររួម នៃក្រុមហ៊ុន អេវើហ្រ្គីន អីភែរីល (ខេមបូឌា) លេខ ០០១/១៩ កប/អក/លបវ. ចុះថ្ងៃទី០២ ខែមករា ឆ្នាំ២០១៩ របស់នាយកដ្ឋានវិវាទការងារ។

**ឃ- ឯកសារបានទទួលពីលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល**

១- លិខិតលេខ ០៣៨ កប/អក/វក/លកអ. ចុះថ្ងៃទី១៤ ខែមករា ឆ្នាំ២០១៩ របស់លេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល ជម្រាបមក លោកក្រុមហ៊ុន អេវើហ្រ្គីន អីភែរីល (ខេមបូឌា) ស្តីពីការជ្រើសរើសអាជ្ញាកណ្តាល។

២- កំណត់ហេតុស្តីពីការចាប់ឆ្នោតជ្រើសរើសអាជ្ញាកណ្តាលពីបញ្ជីឈ្មោះអាជ្ញាកណ្តាលស្នើដោយសមាគមនិយោជក ចុះថ្ងៃទី១៥ ខែមករា ឆ្នាំ២០១៩។

៣- លិខិតអញ្ជើញភាគីនិយោជកចូលរួមសវនាការ លេខ ០៤០ កប/អក/វក/លកអ. ចុះថ្ងៃពុធ ១១កើត ខែបុស្ស ឆ្នាំច សំរឹទ្ធិស័ក ព.ស ២៥៦២ ត្រូវនឹងថ្ងៃទី១៦ ខែមករា ឆ្នាំ២០១៩។

៤- លិខិតអញ្ជើញភាគីកម្មករនិយោជិតចូលរួមសវនាការ លេខ ០៤១ កប/អក/វក/លកអ. ចុះថ្ងៃពុធ ១១កើត ខែបុស្ស ឆ្នាំច សំរឹទ្ធិស័ក ព.ស ២៥៦២ ត្រូវនឹងថ្ងៃទី១៦ ខែមករា ឆ្នាំ២០១៩។

**អង្គហេតុ**

- ក្រោយពីបានពិនិត្យរបាយការណ៍នៃការផ្សះផ្សាវិវាទការងាររួម
- ក្រោយពីបានស្តាប់អំណះអំណាងរបស់តំណាងភាគីកម្មករនិយោជិត
- ក្រោយពីបានពិនិត្យឯកសារបន្ថែម

**ក្រុមប្រឹក្សាអាជ្ញាកណ្តាលរកឃើញថា៖**

- ក្រុមហ៊ុន អេវើហ្រ្គីន អីភែរីល (ខេមបូឌា) (តទៅនេះឱ្យហៅថា "ក្រុមហ៊ុន អេវើហ្រ្គីន") គឺជាក្រុមហ៊ុនដែលមានសកម្មភាពចម្បងក្នុងការកាត់ដេរសម្លៀកបំពាក់ ។ ក្រុមហ៊ុននេះ មានកម្មករនិយោជិតសរុប ចំនួន ១៣៩ នាក់ *(យោងតាមបញ្ជីឈ្មោះកម្មកររោងចក្រ អេវើហ្រ្គីន អីភែរីល (ខេមបូឌា) ដែលដាក់ដោយភាគីកម្មករនិយោជិតនៅថ្ងៃទី២៣ ខែមករា ឆ្នាំ២០១៩ ដែលជាថ្ងៃកំណត់ផ្តល់ឯកសារ)*។
- នាយកដ្ឋានវិវាទការងារ បានចេញលិខិតបញ្ជាក់អ្នកតំណាងភាគីកម្មករនិយោជិតក្នុងការដោះស្រាយវិវាទការងាររួម លេខ ០០១/១៩ កប/អក/លបវ ចុះថ្ងៃទី២ ខែធ្នូ ឆ្នាំ២០១៩ ដែលមានកម្មករនិយោជិត ចំនួន ៤ នាក់ គឺ ១. សន់ ណៃយុន ២. ប៊ុន ផល្លា ៣. ឋាម ថារី និង៤. ជី ចាន់ធឿន ជាអ្នកតំណាងភាគីកម្មករនិយោជិតក្នុងក្រុមហ៊ុន អេវើហ្រ្គីន អីភែរីល (ខេមបូឌា) ក្នុងការដោះស្រាយវិវាទការងាររួម។

THE ARBITRATION COUNCIL

- នៅថ្ងៃសវនាការក្រុមប្រឹក្សាអាជ្ញាកណ្តាល គឺមានវត្តមានរបស់កម្មករនិយោជិតដែលជាតំណាងភាគីកម្មករនិយោជិតទាំងបួននាក់ ដែលមានឈ្មោះនៅក្នុងលិខិតបញ្ជាក់អ្នកតំណាងខាងលើ។
- មិនមានអង្គហេតុណាមួយបញ្ជាក់ថា នៅក្នុងក្រុមហ៊ុននេះ មានសហជីពដែលមានភាពតំណាងបំផុតទេ។

**ចំណុចវិវាទទី១ ទី២ និងទី៣ ៖ ស្នើសុំឱ្យក្រុមហ៊ុនឈប់ព្យួរការងារខុសនីតិវិធីច្បាប់ និងសងលុយត្រឡប់មកកម្មករនិយោជិតវិញពេលព្យួរការងារមិនត្រឹមត្រូវកន្លងមក (ថ្ងៃទី១៨-២១ និង ២៨-២៩ ខែធ្នូ ឆ្នាំ២០១៨) និង សុំឱ្យក្រុមហ៊ុនផ្តល់ការងារឱ្យកម្មករនិយោជិតធ្វើឱ្យបានគ្រប់គ្រាន់**

- នៅក្នុងសវនាការ ភាគីកម្មករនិយោជិតបានសម្រេចបញ្ចូលចំណុចវិវាទទី១, ទី២ និងទី៣ ជាមួយគ្នា។
- ភាគីកម្មករនិយោជិតបញ្ជាក់ការទាមទារថា ឱ្យនិយោជកព្យួរកិច្ចសន្យាការងារស្របតាមនីតិវិធីច្បាប់ និងឱ្យនិយោជកផ្តល់ប្រាក់ឈ្នួល និងចំនួន ៥០ ភាគរយ បន្ថែម ដើម្បីបង្គ្រប់ ១០០ ភាគរយ ក្នុងអំឡុងពេលដែលនិយោជកបានព្យួរកិច្ចសន្យាការងាររបស់កម្មករនិយោជិត ចាប់ពីថ្ងៃទី១៨ ដល់ថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៨ និងចាប់ពីថ្ងៃទី២៨ ដល់ថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០១៨។
- ភាគីកម្មករនិយោជិតបានបញ្ជាក់ពីមូលហេតុនៃការទាមទារថា ៖
    - ០ និយោជកបានជួលកម្មករនិយោជិតឱ្យមកធ្វើការងារ ដូច្នេះ ត្រូវមានការងារឱ្យកម្មករនិយោជិតធ្វើឱ្យបានគ្រប់គ្រាន់។
    - ០ ការព្យួរកិច្ចសន្យាការងាររបស់និយោជក មិនបានអនុវត្តតាមនីតិវិធីច្បាប់ ដោយមិនបានជូនដំណឹង និងសុំការអនុញ្ញាតពីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈទេ។
    - ០ ការផ្តល់ប្រាក់ឈ្នួល ចំនួន ៥០ ភាគរយ ក្នុងអំឡុងពេលព្យួរកិច្ចសន្យាការងារដែលមិនស្របតាមនីតិវិធីនេះ កម្មករនិយោជិតមិនមានប្រាក់គ្រប់គ្រាន់សម្រាប់ចំណាយ។
- ភាគីកម្មករនិយោជិតបានបញ្ជាក់ថា ៖
    - ០ ការព្យួរកិច្ចសន្យាការងារកន្លងមក និយោជកផ្តល់ប្រាក់ឈ្នួលឱ្យកម្មករនិយោជិតចំនួន ៥០ ភាគរយ ដោយនិយោជកប្រាប់កម្មករនិយោជិតដោយផ្ទាល់មាត់ ទើបនិយោជកបិទប្រកាសនៅក្លោងទ្វាររោងចក្រឱ្យកម្មករនិយោជិតដឹងតាមក្រោយ។
    - ០ នៅក្នុងខែធ្នូ ឆ្នាំ២០១៨ និយោជកបានព្យួរកិច្ចសន្យាការងាររបស់កម្មករនិយោជិត ចំនួន ៥ ថ្ងៃ ដោយមិនស្របតាមនីតិវិធីច្បាប់ ដោយផ្តល់ប្រាក់ឈ្នួល ចំនួន ៥០ ភាគរយ។
    - ០ សម្រាប់ការព្យួរកិច្ចសន្យាការងារ ចាប់ថ្ងៃទី១៨ ដល់ថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៨ គឺនិយោជកបានហៅកម្មករនិយោជិតទាំងអស់មកប្រាប់ថា និយោជកសម្រេចព្យួរកិច្ចសន្យាការងាររបស់កម្មករនិយោជិតដោយផ្តល់ប្រាក់ឈ្នួល ចំនួន ៥០ ភាគរយ កំឡុងពេលព្យួរការងារនេះ។
    - ០ ចំពោះការព្យួរការងារ ពីថ្ងៃទី២៨ ដល់ថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០១៨ គឺកម្មករនិយោជិតបានទទួលដំណឹងតាមរយៈអ្នកបកប្រែ ដោយផ្តល់ប្រាក់ឈ្នួលចំនួន ៥០ ភាគរយ កំឡុងពេលព្យួរការងារនេះ

ARBITRATION COUNCIL

- កម្មករនិយោជិតបានបន្តមករោងចក្រជាធម្មតា នៅថ្ងៃនៃកាលបរិច្ឆេទការព្យួរកិច្ចសន្យាការងារទាំងពីរ ខាងលើ។
- និយោជកបានប្រាប់មូលហេតុនៃការព្យួរការងារទៅកម្មករនិយោជិតថា ដោយសារគ្មានអ្នកបញ្ជាទិញ និងគ្មានការងារឱ្យកម្មករនិយោជិតធ្វើ។
- រហូតមកដល់ថ្ងៃសវនាការនេះ ក៏និយោជកមិនមានការងារឱ្យកម្មករនិយោជិតធ្វើដែរ។ ប៉ុន្តែ មានបិទប្រកាសឱ្យកម្មករនិយោជិតមកធ្វើការ ចំនួន ២ ថ្ងៃ ក្នុងមួយសប្តាហ៍ ដោយមានកាលបរិច្ឆេទនៃថ្ងៃដែលឱ្យកម្មករនិយោជិតមកធ្វើការខុសៗគ្នា។
- នៅក្នុងក្រុមហ៊ុនមិនមានបុគ្គលិករដ្ឋបាលណាម្នាក់ នៅធ្វើការទេ ដោយបានបញ្ជាក់បន្ថែមថា នៅកំឡុងថ្ងៃទី០២ ឬទី០៣ ខែមករា ឆ្នាំ២០១៩ កម្មករនិយោជិត បានទូរស័ព្ទទៅរដ្ឋបាលក្រុមហ៊ុន ដើម្បីសួរនាំចំពោះករណីដែលក្រុមហ៊ុនដកម៉ាស៊ីនស្តេនវត្តមានចេញ ហើយរដ្ឋបាលរូបនោះបានប្រាប់មកកម្មករនិយោជិតវិញថា រូបគាត់បានលាឈប់ពីក្រុមហ៊ុនហើយ។ បន្ទាប់មកកម្មករនិយោជិតបានបន្តទាក់ទងតាមរយៈទូរស័ព្ទទៅអ្នកបកប្រែឈ្មោះថា បង វី ក៏បានប្រាប់មកវិញថា រូបគាត់បានលាឈប់ពីក្រុមហ៊ុន អេវើហ្គ្រីន ហើយដែរ។
- គិតមកដល់ថ្ងៃសវនាការនេះ នៅក្នុងក្រុមហ៊ុនមិនមានបុគ្គលិករដ្ឋបាលមកធ្វើការទៀតទេ គឺមានតែកម្មករនិយោជិតតែប៉ុណ្ណោះ។

**ហេតុផលនៃសេចក្តីសម្រេច ÷**

មុននឹងពិចារណាចំណុចទាមទារនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលបកស្រាយអំពីនីតិវិធីអាជ្ញាកណ្តាល នៅពេលអវត្តមានភាគីនិយោជក និងអំពីភាគីដើមបណ្តឹងជាមុនសិន ៖

**ក. អវត្តមានរបស់ភាគីនិយោជក**

នៅក្នុងសវនាការ ភាគីនិយោជកមិនមានវត្តមាន តាមការអញ្ជើញរបស់លេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញា-កណ្តាលទេ។

ក្រុមប្រឹក្សាអាជ្ញាកណ្តាលធ្វើការពិចារណាថា តើក្រុមប្រឹក្សាអាជ្ញាកណ្តាលអាចធ្វើសវនាការដោយអវត្តមានភាគីនិយោជក ដែរ ឬទេ?

ប្រការ ២១ នៃប្រកាសលេខ ០៩៩ ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៤ ចែងថា ៖ *"ក្នុងករណីភាគីណាមួយបានទទួលការអញ្ជើញត្រឹមត្រូវហើយ តែបែរជាខកខានមិនបានបង្ហាញខ្លួន នៅចំពោះមុខក្រុមអាជ្ញាកណ្តាល ដោយគ្មានបង្ហាញមូលហេតុត្រឹមត្រូវ ក្រុមអាជ្ញាកណ្តាលអាចបន្តដំណើរការរបស់ខ្លួនក្នុងពេលដែលភាគីនោះអវត្តមាន ឬអាចបញ្ចប់ដំណើរការអាជ្ញាកណ្តាលដោយចេញសេចក្តីបង្គាប់"*។

ទាក់ទងនឹងខ្លឹមសារនៃប្រការ២១ នៃប្រកាសលេខ ០៩៩ នៅក្នុងសំណុំរឿងមុនៗ ក្រុមប្រឹក្សាអាជ្ញា-កណ្តាល បានបកស្រាយថា នៅពេលដែលភាគីនិយោជកបានទទួលការអញ្ជើញត្រឹមត្រូវហើយ តែបែរជាខកខានមិនបានបង្ហាញខ្លួននៅចំពោះមុខក្រុមអាជ្ញាកណ្តាល ដោយគ្មានបង្ហាញមូលហេតុត្រឹមត្រូវ ក្រុមអាជ្ញាកណ្តាលអាច-

សម្រេចបន្តដំណើរការរបស់ខ្លួន ដោយធ្វើការបើកសវនាការកំបាំងមុខភាគីនិយោជក ដែលអវត្តមាននោះបាន។ *(សូមមើលសេចក្តីបង្គាប់អាជ្ញាកណ្តាលលេខ ៥៣/០៤-គួង ហុង, លេខ ៦៣/០៤-សាញ វ៉ែល, លេខ ១៤៨/០៧-ប៉ាយ ហឺ, លេខ ៩៩/០៩-ឃីង ឡៃន, លេខ ១៧៣/១១-ជិន អ៊ីង, លេខ ១៤២/១២-អប្សរា, លេខ ១០៩/១៣-វិទ្យាស្ថាន ប៊ុណ្ណា កម្ពុជា, លេខ ១៦៣/១៤-ស៊ីន ឆាង ស៊ីង ហ្គាមេន (ខេមបូឌា), លេខ ២៥០/១៥-អិល អិល អេស ព្រីនធីង, លេខ ០២២/១៦-អាត់តាខីស (ខេមបូឌា) ហ្គាមេន និង លេខ ១២៨/១៦-សេង ហុង យាន អ៊ីមប្រយឌើរី ខូអិលធីឌី), លេខ ១៨៥/១៦-តុង ផៃ ហ្វេស៊ិន តិចតូលូជី អិលធីឌី និង លេខ ១៦៥/១៦-ខេមបូឌាន សាន់វ៉ាយ ហ្គាមេន ខូអិលធីឌី, ១២៩/១៥-វេងហួរ ហ្គាមេន ខូ អិលធីឌី )*

ក្រុមប្រឹក្សាអាជ្ញាកណ្តាលនៅក្នុងសំណុំរឿងនេះ ក៏យល់ស្របតាមការបកស្រាយរបស់ក្រុមប្រឹក្សាអាជ្ញា-កណ្តាល នៅក្នុងសំណុំរឿងខាងលើនេះដែរ។

នៅថ្ងៃទី១៦ ខែមករា ឆ្នាំ២០១៩ វេលាម៉ោង ១១ និង ២០ នាទីព្រឹក មន្ត្រីលេខាធិការដ្ឋាននៃក្រុមប្រឹក្សាអាជ្ញាកណ្តាលបានធ្វើការទាក់ទងទៅកាន់លោក សួង ហួត ដែលជាមន្ត្រីនៃសមាគមន៍រោងចក្រកាត់ដេរនៅកម្ពុជា ហៅកាត់ថា GMAC ដើម្បីជូនដំណឹងស្តីពីកាលបរិច្ឆេទសវនាការដល់ភាគីនិយោជក។ លេខាធិការដ្ឋានបានជម្រាបទៅកាន់លោក សួង ហួត ដោយបញ្ជាក់ពីព័តិមាននៃលិខិតអញ្ជើញចូលរួមសវនាការ ក្រុមប្រឹក្សាអាជ្ញាកណ្តាល លេខ ០៤០ កប/អក/វក/លកអ. ចុះថ្ងៃទី១៦ ខែមករា ឆ្នាំ២០១៩ ដែលមានភ្ជាប់ជាមួយនូវព័តិមានច្បាស់លាស់ អំពីកាលបរិច្ឆេទនៃសវនាការនាថ្ងៃទី២២ ខែមករា ឆ្នាំ២០១៩ វេលាម៉ោង ១៤ និង ០០ នាទី រសៀល ទីកន្លែងនៃសវនាការ ព្រមទាំងលេខទូរស័ព្ទ/ទូរសារ សម្រាប់ទំនាក់ទំនងមកក្រុមប្រឹក្សាអាជ្ញាកណ្តាលផងដែរ។

ដោយឡែក ភាគីនិយោជកមិនមានវត្តមាននៅក្នុងសវនាការរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាល តាមការអញ្ជើញនោះទេ ប៉ុន្តែ មានវត្តមានលោក សួង ហួត ដែលជាមន្ត្រីនៃសមាគមន៍រោចក្រកាត់ដេរនៅកម្ពុជា ដោយបានបញ្ជាក់ថា ថៅកែក្រុមហ៊ុន មិនមានវត្តមាននៅក្នុងប្រទេសកម្ពុជាទេ ដោយគាត់បានត្រឡប់នៅប្រទេសកំណើតរបស់គាត់វិញ ដើម្បីចូលរួមពិធីបុណ្យសពរបស់ឪពុកគាត់។ ម៉្យាងវិញទៀត ថៅកែក្រុមហ៊ុនក៏មិនមានធ្វើលិខិតផ្ទេរសិទ្ធិឱ្យគាត់ ដើម្បីធ្វើជាតំណាងក្នុងការដោះស្រាយវិវាទការងារក្នុងសំណុំរឿងនេះទេ ហើយវត្តមានរបស់លោក នៅថ្ងៃសវនាការនេះ គឺដើម្បីពាំនាំនៅជំហររបស់និយោជកក្នុងការផ្តល់ប្រាក់បំណាច់ផ្តាច់កិច្ចសន្យាការងាររបស់កម្មករ និយោជិតតែប៉ុណ្ណោះ។

ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា ភាគីនិយោជកខកខានមិនបានមកបង្ហាញខ្លួននៅចំពោះមុខក្រុមប្រឹក្សាអាជ្ញាកណ្តាល ដោយគ្មានបង្ហាញមូលហេតុត្រឹមត្រូវ ឬផ្តល់ព័តិមានណាមួយសម្រាប់ការមិនចូលរួមនេះទេ។

យោងតាមប្រការ ២១ នៃប្រកាសលេខ ០៩៩ ខាងលើ លេខាធិការដ្ឋាននៃក្រុមប្រឹក្សាអាជ្ញាកណ្តាលបានធ្វើការអញ្ជើញនិយោជកឱ្យមកចូលរួមក្នុងសវនាការអាជ្ញាកណ្តាលត្រឹមត្រូវហើយ តែភាគីនិយោជកបែរជាមិនមកចូលរួមសវនាការ ហើយមិនបានផ្តល់មូលហេតុត្រឹមត្រូវណាមួយអំពីការមិនបានចូលរួមសវនាការរបស់ក្រុមប្រឹក្សា-អាជ្ញាកណ្តាលនោះទេ។ ហេតុនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលអាចបន្តដំណើរការរបស់ខ្លួន ក្នុងពេលដែលភាគីនិយោជកអវត្តមានបាន។

ARBITRATION COUNCIL

នៅក្នុងសំណុំរឿងនេះ ក្រុមប្រឹក្សាអាជ្ញាកណ្ដាលសម្រេចបន្តដំណើរការរបស់ខ្លួន ដោយអវត្តមានរបស់ភាគីនិយោជក និងចំពោះមុខភាគីកម្មករនិយោជិត ដើម្បីវិនិច្ឆ័យលើសំណុំរឿង ដែលបានបញ្ជូនមកក្រុមប្រឹក្សាអាជ្ញាកណ្ដាលនេះ ដោយផ្អែកលើភស្តុតាង និងការបកស្រាយបំភ្លឺរបស់ភាគីកម្មករនិយោជិតនៅក្នុងសវនាការ។

**ខ. ដើមបណ្ដឹង**

កថាខណ្ឌទី១ នៃមាត្រា ៥៤ នៃច្បាប់ស្ដីពីសហជីព ចុះថ្ងៃទី១៧ ខែឧសភា ឆ្នាំ២០១៦ ចែងថា ៖ *"ភាពជាតំណាងបំផុតនៃសហជីពត្រូវបានទទួលស្គាល់នៅក្នុងក្របខ័ណ្ឌនៃសហគ្រាស ឬគ្រឹះស្ថាន។ សម្រាប់គោលបំណងនៃការចរចាអនុសញ្ញារួម ឬដោះស្រាយវិវាទការងាររួម គឺសហជីពដែលមានភាពជាតំណាងបំផុតទទួលបានសិទ្ធិផ្ដាច់មុខ។"* ។

យោងតាមខ្លឹមសារនៃកថាខណ្ឌទី១ នៃមាត្រា ៥៤ នៃច្បាប់ស្ដីពីសហជីពខាងលើនេះ ក្រុមប្រឹក្សាអាជ្ញាកណ្ដាលយល់ថា មានតែសហជីពដែលមានភាពជាតំណាងបំផុតប៉ុណ្ណោះ ដែលមានសិទ្ធិផ្ដាច់មុខនៅក្នុងការចរចាបង្កើតអនុសញ្ញារួម និងដោះស្រាយវិវាទការងាររួមនៅក្នុងសហគ្រាស ឬគ្រឹះស្ថានរបស់ខ្លួន។ សិទ្ធិផ្ដាច់មុខក្នុងការដោះស្រាយវិវាទការងាររួមនេះ សំដៅលើសិទ្ធិក្នុងការនាំយកវិវាទ និងធ្វើជាតំណាងឱ្យកម្មករនិយោជិតនៅគ្រប់នីតិវិធីដោះស្រាយវិវាទការងាររួម ដោយរួមបញ្ចូលទាំងនីតិវិធីដោះស្រាយវិវាទនៅក្រុមប្រឹក្សាអាជ្ញាកណ្ដាលផងដែរ។ *(សូមមើលបន្ថែមសេចក្ដីបង្គាប់អាជ្ញាកណ្ដាល លេខ ១៨០/១៦-ស៊ីម៉ង់ត៍ កម្ពុជា ចក្រីទីង និងលេខ ១៧១/១៦-ដេវើលីន ខូអិលធីឌី)*

នៅក្នុងសំណុំរឿងនេះ មិនមានអង្គហេតុណាមួយបញ្ជាក់ថា នៅក្នុងក្រុមហ៊ុននេះ មានសហជីពដែលមានភាពតំណាងបំផុតទេ។

ប្រការ ១៦ នៃប្រកាសលេខ ៣០៣ ក.ប/ប្រ.ក.គ.ប.ក ស្ដីពីភាពជាតំណាងបំផុតនៃសហជីព និងបែបបទ និងនីតិវិធីដើម្បីទទួលបានភាពជាតំណាងបំផុត ចុះថ្ងៃទី២ ខែកក្កដា ឆ្នាំ២០១៨ ចែងថា ៖ *"ក្នុងករណីសហគ្រាស គ្រឹះស្ថានដែលពុំទាន់មានសហជីព ឬពុំទាន់មានសហជីពដែលមានភាពជាតំណាងបំផុត ការដោះស្រាយវិវាទការងាររួម ត្រូវដោះស្រាយដោយអ្នកតំណាងកម្មករនិយោជិត។"* ។

លើសពីនេះ ប្រការ១ នៃប្រកាសលេខ ៣៦២ ក.ប/ប្រ.ក ស្ដីពីការធ្វើប្រតិភូកម្មមុខងារក្នុងការធ្វើបណ្ដឹងអំពីវិវាទការងាររួម និងចេញលិខិតទទួលស្គាល់ប្រតិភូក្រុមប្រឹក្សាចរចា ចុះថ្ងៃទី២៥ ខែសីហា ឆ្នាំ២០១៦ របស់ក្រសួងការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈ ចែងថា ៖ *"ត្រូវបានធ្វើប្រតិភូកម្មជូនដល់ប្រធាននាយកដ្ឋានវិវាទការងារ និងប្រធានមន្ទីរការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈខេត្ត នូវមុខងារ ដូចខាងក្រោម ៖*

...

*- ចេញលិខិតទទួលស្គាល់ប្រតិភូក្រុមប្រឹក្សាចរចា សម្រាប់ដោះស្រាយវិវាទការងាររួម។"* ។

យោងតាមប្រការ១ នៃប្រកាសលេខ ៣៦២ ក.ប/ប្រ.ក ខាងលើ ក្រុមប្រឹក្សាអាជ្ញាកណ្ដាលយល់ថា នាយកដ្ឋានវិវាទការងារ និងប្រធានមន្ទីរការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈខេត្ត មានមុខងារក្នុងការទទួលស្គាល់កម្មករនិយោជិត ឱ្យធ្វើជាតំណាងរបស់ភាគីកម្មករនិយោជិត ដើម្បីដោះស្រាយវិវាទការងាររួម។ ដូច្នេះ កម្មករ

និយោជិតដែលត្រូវបានទទួលស្គាល់ដោយនាយកដ្ឋានវិវាទការងារ ឬប្រធានមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្ត មានសិទ្ធិស្របច្បាប់ក្នុងការតំណាងឱ្យភាគីកម្មករនិយោជិត ដើម្បីដោះស្រាយវិវាទការងាររួម ដោយរួមទាំងនៅដំណាក់កាលដោះស្រាយវិវាទការងារនៅក្រុមប្រឹក្សាអាជ្ញាកណ្តាលផងដែរ នៅពេលមិនទាន់មានវត្តមានរបស់សហជីពមានភាពតំណាងបំផុត។ (*សូមមើលសេចក្តីបង្គាប់អាជ្ញាកណ្តាល លេខ ២២៧/១៦-យូនីកតា ថេកណឡូជី (ខេមបូឌា), លេខ ២២៨/១៦-កាស៊ីណូកោះមាស និង សណ្ឋាគារ, លេខ ០០៨/១៧-ថបវើលដ៍ ហ្គាមិន (ខេមបូឌា) អិលធីឌី និង លេខ ២៣៧/១៦-ហ្សិណា-ដាយដុង (ខេមបូឌា) អេឡិចត្រូនិច*)។

ក្រុមប្រឹក្សាអាជ្ញាកណ្តាលនៅក្នុងសំណុំរឿងនេះ ក៏យល់ស្របទៅនឹងការបកស្រាយរបស់ក្រុមប្រឹក្សាអាជ្ញា-កណ្តាលនៅក្នុងសំណុំរឿងមុនៗ ខាងលើដែរ។

នាយកដ្ឋានវិវាទការងារ បានចេញលិខិតបញ្ជាក់អ្នកតំណាងភាគីកម្មករនិយោជិត ក្នុងការដោះស្រាយវិវាទការងាររួម លេខ ០០១/១៩ កប/អក/លបវ ចុះថ្ងៃទី០២ ខែមករា ឆ្នាំ២០១៩ ដែលមានកម្មករនិយោជិត ចំនួន ៤ នាក់ គឺ ១. សន់ ណៃយុន ២. ប៊ុន ផល្លា ៣. ហាម ថារី និង៤. ជី ចាន់ធឿន ជាអ្នកតំណាងភាគីកម្មករនិយោជិតនៃក្រុមហ៊ុន អេវើហ្គ្រីន អឺភែរីល (ខេមបូឌា) ក្នុងការដោះស្រាយវិវាទការងាររួម។ នៅថ្ងៃសវនាការក្រុមប្រឹក្សាអាជ្ញាកណ្តាល គឺមានវត្តមានរបស់កម្មករនិយោជិតដែលជាអ្នកតំណាងភាគីកម្មករនិយោជិតទាំងបួននាក់ ដែលមានឈ្មោះនៅក្នុងលិខិតបញ្ជាក់អ្នកតំណាងខាងលើ។

ហេតុនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា កម្មករនិយោជិត ចំនួន ០៤ នាក់ ខាងលើ មានសិទ្ធិធ្វើជាតំណាងកម្មករនិយោជិត នៃក្រុមហ៊ុន អេវើហ្គ្រីន អឺភែរីល (ខេមបូឌា) ក្នុងការដោះស្រាយវិវាទការងាររួមនៅក្រុមប្រឹក្សាអាជ្ញាកណ្តាល ស្របតាមប្រការ១ នៃប្រកាសលេខ ៣៦២ ក.ប/ប្រ.ក ខាងលើ។

សរុបមក ក្រុមប្រឹក្សាអាជ្ញាកណ្តាលពិចារណាចំណុចវិវាទនៅក្នុងសំណុំរឿងនេះ សម្រាប់កម្មករនិយោជិតនៅក្នុងក្រុមហ៊ុន អេវើហ្គ្រីន អឺភែរីល (ខេមបូឌា)។

**ចំណុចវិវាទទី១ ទី២ និងទី៣ ៖** *ភាគីកម្មករនិយោជិតទាមទារឱ្យនិយោជកព្យួរកិច្ចសន្យាការងារស្របតាមនីតិវិធីច្បាប់ និងឱ្យនិយោជកផ្តល់ប្រាក់ឈ្នួល និងចំនួន ៥០ ភាគរយ បន្ថែម ដើម្បីបង្គ្រប់ ១០០ ភាគរយ ក្នុងអំឡុងពេលដែលនិយោជកបានព្យួរកិច្ចសន្យាការងាររបស់កម្មករនិយោជិត ចាប់ពីថ្ងៃទី១៨ ដល់ថ្ងៃទី ២១ ខែធ្នូ ឆ្នាំ២០១៨ និងចាប់ពីថ្ងៃទី២៨ ដល់ថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០១៨*

**ក្រុមប្រឹក្សាអាជ្ញាកណ្តាលពិចារណាថា តើការព្យួរកិច្ចសន្យាការងាររបស់កម្មករនិយោជិត ចាប់ពីថ្ងៃទី១៨ ដល់ថ្ងៃទី១២ ខែធ្នូ ឆ្នាំ២០១៨ និងចាប់ពីថ្ងៃទី២៨ ដល់ថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០១៨ បានធ្វើឡើងត្រឹមត្រូវតាមនីតិវិធីច្បាប់ស្តីពីការងារដែរ ឬទេ?**

កថាខណ្ឌទី ១១ មាត្រា ៧១ នៃច្បាប់ស្តីពីការងារ ឆ្នាំ១៩៩៧ ចែងថា ៖ "*ពេលណាដែលសហគ្រាសជួបការលំបាកផ្នែកសេដ្ឋកិច្ច ឬសំភារៈធូន់ធ្ងរ ឬការលំបាកជាពិសេសណាមួយ ដែលនាំឱ្យព្យួរសកម្មភាពសហគ្រាសមិនលើសពីពីរខែ។ ការព្យួរសកម្មភាពនេះ ត្រូវដាក់ឱ្យស្ថិតនៅក្រោមការត្រួតពិនិត្យរបស់អធិការការងារ។*

នៅក្នុងសំណុំរឿងមុនៗ ក្រុមប្រឹក្សាអាជ្ញាកណ្ដាលបានបកស្រាយ កថាខណ្ឌទី ១១ នៃ មាត្រា ៧១ ខាងលើថា ៖ *"ការលំបាកផ្នែកសំភារៈ ឬសេដ្ឋកិច្ចធ្ងន់ធ្ងរនេះ ជាហេតុផលដែលអាចអនុញ្ញាតឱ្យនិយោជកអាចព្យួរការងារ ប្រសិនបើនិយោជកបំពេញលក្ខខណ្ឌ ២ យ៉ាងគឺ ៖*

*- ការព្យួរសកម្មភាពនេះ ត្រូវដាក់ឱ្យស្ថិតនៅក្រោមការត្រួតពិនិត្យរបស់អធិការកិច្ចការងារ និង*

*- ការព្យួរការងារនេះមិនត្រូវឱ្យលើសពី ២ ខែ ។"*

*(សូមមើលហេតុផលនៃសេចក្ដីសម្រេចក្នុង សំណុំរឿងលេខ ៥៨/០៧-៨ ស្តារ ស្ពតវែរ, ០០៨/១៧-ថបវើលដ៏ ហ្គាមិន (ខេមបូឌា) អិលធីឌី ចំណុចវិវាទទី១)*

លើសពីនេះ ហេតុផលសេចក្ដីសម្រេចរបស់ក្រុមប្រឹក្សាអាជ្ញាកណ្ដាលក្នុងសំណុំរឿងមុនៗ បានបកស្រាយកថាខណ្ឌទី១១ នៃមាត្រា ៧១ ថា ៖ *"ការព្យួរសកម្មភាពនេះ ត្រូវដាក់ឱ្យស្ថិតនៅក្រោមការត្រួតពិនិត្យរបស់អធិការការងារ គឺមានន័យថា និយោជកត្រូវគោរពតាមកាតព្វកិច្ចនៃការជូនដំណឹង និង ទទួលបានការអនុញ្ញាតជាមុនពីអធិការការងារ ទើបអាចព្យួរការងារដោយស្របច្បាប់បាន ។" (សូមមើលសេចក្ដីបង្គាប់អាជ្ញាកណ្ដាលលេខ ៧២/០៥-ណាត ហ្គេអ៊ីធី ហេតុផលនៃចំណុចវិវាទទី១, លេខ ២២/០៥-អូសេអង់ ហេតុផលនៃចំណុចវិវាទទី២, លេខ ១៩៨/១៣-ស៊ូ អ៊ីភែវីល (ខេមបូឌា) ហេតុផលនៃចំណុចវិវាទទី២, លេខ ១៦០/១៤-អូសេអង់ ហ្គាមិន ខូអិលធីឌី លេខ ០៨/០៧-ស៊ាវ គីញ ចំណុចវិវាទទី២, លេខ ០០៨/១៧-ថបវើលដ៏ ហ្គាមិន (ខេមបូឌា) អិលធីឌី ចំណុចវិវាទទី១)*

ក្រុមប្រឹក្សាអាជ្ញាកណ្ដាលនៅក្នុងសំណុំរឿងនេះ ក៏យល់ស្របចំពោះការបកស្រាយរបស់ក្រុមប្រឹក្សាអាជ្ញា-កណ្ដាលខាងលើ ដោយយល់ថា និយោជកអាចព្យួរកិច្ចសន្យាការងារក្រោមហេតុផលនៃការលំបាកផ្នែកសម្ភារៈ ឬសេដ្ឋកិច្ចធ្ងន់ធ្ងរបាន លុះត្រាតែការព្យួរកិច្ចសន្យាការងារ ត្រូវដាក់ឱ្យស្ថិតនៅក្រោមការត្រួតពិនិត្យរបស់អធិការកិច្ចការងារ តាមរយៈការទទួលការអនុញ្ញាតពីអធិការការងារជាមុន។

លើសពីនេះ កថាខណ្ឌទី១ មាត្រា៧២ នៃច្បាប់ស្ដីពីការងារ ឆ្នាំ១៩៩៧ ចែងថា ៖ *"ការព្យួរកិច្ចសន្យាការងារនាំឱ្យប៉ះពាល់តែកាតព្វកិច្ចសំខាន់ៗនៃកិច្ចសន្យាការងារ ពោលគឺកាតព្វកិច្ចដែលកម្មករនិយោជិតត្រូវធ្វើការឱ្យនិយោជក និងកាតព្វកិច្ចដែលនិយោជកត្រូវផ្ដល់ប្រាក់ឈ្នួលដល់កម្មករនិយោជិត លើកលែងតែមានបទប្បញ្ញត្តិផ្ទុយដែលកំណត់ឱ្យនិយោជកផ្ដល់ប្រាក់ឈ្នួលឱ្យកម្មករនិយោជិត ។"*

ផ្អែកតាមកថាខណ្ឌទី១ មាត្រា ៧២ នៃច្បាប់ស្ដីពីការងារ ខាងលើ និយោជកមិនមានកាតព្វកិច្ចផ្ដល់ប្រាក់ឈ្នួលឱ្យកម្មករនិយោជិតទេ នៅពេលមានការព្យួរកិច្ចសន្យាការងារ ប៉ុន្តែ កថាខណ្ឌទី១ នៃមាត្រា ៧២ ខាងលើ ត្រូវបានអនុវត្តនៅពេលដែលការព្យួរកិច្ចសន្យាការងារធ្វើឡើងដោយស្របតាមនីតិវិធីច្បាប់ប៉ុណ្ណោះ។

នៅក្នុងសេចក្ដីបង្គាប់អាជ្ញាកណ្ដាលមុនៗ ក្រុមប្រឹក្សាអាជ្ញាកណ្ដាលយល់ឃើញថា ៖ *"ប្រសិនបើក្រុមហ៊ុនបានធ្វើបែបបទព្យួរការងារ ត្រឹមត្រូវតាមច្បាប់ស្ដីពីការងារ ដោយការព្យួរកិច្ចសន្យាការងារនោះ ត្រូវបានស្ថិតនៅក្រោមការត្រួតពិនិត្យពីអធិការកិច្ចការងារនោះ ក្រុមហ៊ុនមិនមានកាតព្វកិច្ច ត្រូវផ្ដល់ប្រាក់ឈ្នួលដល់កម្មករនិយោជិតឡើយ ។ ប៉ុន្តែ ប្រសិនបើក្រុមហ៊ុនមិនបានគោរពតាមច្បាប់ស្ដីពីការងារ នៃការព្យួរកិច្ចសន្យាការងារកម្មករនិយោជិត*

THE ARBITRATION COUNCIL

*ដូចបានរៀបរាប់ខាងលើទេនោះ ក្រុមហ៊ុនមានកាតព្វកិច្ចផ្តល់ប្រាក់ឈ្នួល ១០០ ភាគរយ ព្រមទាំងអត្ថប្រយោជន៍ផ្សេងៗ ដល់កម្មករនិយោជិត ទោះបីជាក្រុមហ៊ុនពុំមានការងារឱ្យកម្មករនិយោជិតធ្វើក៏ដោយ ។" (សូមមើលសេចក្តីបង្គាប់អាជ្ញាកណ្តាលលេខ ២១/០៣-ឡយ អ័ល ខេមបូឌា ហេតុផលនៃចំណុចវិវាទទី៨, លេខ ០១/០៤-ញូវ ភាញ់ ២, លេខ ៦០/០៦-ញូវមេក ហ្គាមេន ហេតុផលនៃចំណុចវិវាទទី២, លេខ ៧៤/០៧-ក្លូបលអាប៉ារ៉ែល ហេតុផលនៃចំណុចវិវាទទី១, លេខ ២៧/០៨-អាក ឃីត ហេតុផលនៃចំណុចវិវាទទី៦, លេខ ១០៩/០៩-យូ អេស អេ ហេតុផលនៃចំណុចវិវាទទី៤, លេខ ០០៨/១៧-ផបវើលដ៍ ហ្គាមិន (ខេមបូឌា) អិលធីឌី ចំណុចវិវាទទី១)*

ក្រុមប្រឹក្សាអាជ្ញាកណ្តាលនៅក្នុងសំណុំរឿងនេះ ក៏យល់ស្របចំពោះការបកស្រាយរបស់ក្រុមប្រឹក្សាអាជ្ញា-កណ្តាលនៅក្នុងសំណុំរឿងខាងលើដែរ ។

យោងតាមអង្គហេតុ ភាគីកម្មករនិយោជិតបានអះអាង ចាប់ពីថ្ងៃទី១៨ ដល់ថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៨ និង ចាប់ពីថ្ងៃទី២៨ ដល់ថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០១៨ និយោជកបានព្យួរកិច្ចសន្យាការងាររបស់កម្មករនិយោជិតមិនស្រប តាមនីតិវិធីច្បាប់ ដោយសារមិនមានការអនុញ្ញាតពីអធិការការងារទេ ។ ការព្យួរនេះ គឺនិយោជកបានផ្តល់ប្រាក់ឈ្នួល ចំនួន ៥០ ភាគរយ ។

ភាគីនិយោជកបានបោះបង់សិទ្ធិរបស់ខ្លួន ក្នុងការឆ្លើយតបនៅចំពោះមុខក្រុមប្រឹក្សាអាជ្ញាកណ្តាលទាក់ទង ទៅនឹងការលើកឡើងរបស់ភាគីកម្មករនិយោជិត ដោយមិនបានចូលរួមសវនាការអាជ្ញាកណ្តាល ។ ដូចនេះ ក្រុមប្រឹក្សា អាជ្ញាកណ្តាលសម្រេចទទួលស្គាល់ការលើកឡើងរបស់ភាគីកម្មករនិយោជិត ។

ហេតុនេះ យោងតាមកថាខណ្ឌទី១១ មាត្រា ៧១ និងចំណុចទី១ មាត្រា ៧២ នៃច្បាប់ស្តីពីការងារ និងការ បកស្រាយរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាលនៅក្នុងសំណុំរឿងមុនៗខាងលើ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា ការព្យួរកិច្ចសន្យាការងារនេះ គឺមិនបានធ្វើឡើងស្របតាមនីតិវិធីនៃច្បាប់ស្តីពីការងារទេ ព្រោះថា ការព្យួរកិច្ចសន្យា ការងារនេះ មិនមានលិខិតអនុញ្ញាតពីអធិការការងារទេ ។

ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា និយោជកត្រូវតែអនុវត្តការព្យួរកិច្ចសន្យាការងាររបស់កម្មករ និយោជិតឱ្យស្របតាមនីតិវិធីនៃច្បាប់ស្តីពីការងារ ។

យោងតាមអង្គហេតុ និយោជកបានផ្តល់ប្រាក់ឈ្នួល ចំនួន ៥០ ភាគរយ រួចហើយ ចំពោះរយៈពេលនៃការ ព្យួរកិច្ចសន្យាការងាររបស់កម្មករនិយោជិតទាំងពីរលើកខាងលើ ដូច្នេះ និយោជកមានកាតព្វកិច្ចផ្តល់ប្រាក់ឈ្នួល ចំនួន ៥០ ភាគរយ បន្ថែមទៀត ដើម្បីបង្គ្រប់ ១០០ ភាគរយ ជូនកម្មករ និយោជិតក្នុងកំឡុងពេលនៃការព្យួរកិច្ចសន្យា ការងារ ដែលមិនស្របតាមនីតិវិធីច្បាប់ស្តីពីការងារនេះ ។

សរុបសេចក្តីមក ក្រុមប្រឹក្សាអាជ្ញាកណ្តាលសម្រេច បង្គាប់ឱ្យនិយោជកអនុវត្តការព្យួរកិច្ចសន្យាការងារ របស់កម្មករនិយោជិតស្របតាមនីតិវិធីច្បាប់ស្តីពីការងារ និងបង្គាប់ឱ្យនិយោជកផ្តល់ប្រាក់ឈ្នួល ចំនួន ៥០ ភាគរយ បន្ថែម បង្គ្រប់ ១០០ ភាគរយ ជូនកម្មករនិយោជិតក្នុងអំឡុងពេលព្យួរកិច្ចសន្យា ការងារមិនស្របតាមនីតិវិធីច្បាប់ ស្តីពីការងារ ចាប់តាំងពីថ្ងៃទី១៨ ដល់ថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៨ និងចាប់ពីថ្ងៃទី២៨ ដល់ថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០១៨ ។

THE ARBITRATION COUNCIL

យោងតាមអង្គហេតុ អង្គច្បាប់ និងហេតុផលដូចបានបញ្ជាក់ខាងលើ ក្រុមប្រឹក្សាអាជ្ញាកណ្តាលសម្រេចចេញសេចក្តីបង្គាប់ ដូចតទៅ ៖

## សម្រេច និង បង្គាប់

**ចំណុចវិវាទទី១ ទី២ និងទី៣ ៖**

- បង្គាប់ឱ្យនិយោជកអនុវត្តការព្យួរកិច្ចសន្យាការងាររបស់កម្មករនិយោជិត ស្របតាមនីតិវិធីច្បាប់ស្តីពីការងារ និងបង្គាប់ឱ្យនិយោជកផ្តល់ប្រាក់ឈ្នួល ចំនួន ៥០ ភាគរយ បន្ថែម បង្គ្រប់ ១០០ ភាគរយ ជូនកម្មករនិយោជិត ក្នុងអំឡុងពេលព្យួរកិច្ចសន្យាការងារមិនស្របតាមនីតិវិធីច្បាប់ស្តីពីការងារ ចាប់តាំងពីថ្ងៃទី១៨ ដល់ថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៨ និងចាប់ពីថ្ងៃទី២៨ ដល់ថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០១៨។

**ប្រភេទនៃសេចក្តីបង្គាប់ ៖ សេចក្តីបង្គាប់មិនជាប់កាតព្វកិច្ច**

*សេចក្តីបង្គាប់នេះ នឹងក្លាយជាស្ថាពរ បន្ទាប់ពីថ្ងៃជូនដំណឹងអំពីសេចក្តីបង្គាប់ចំនួន ០៨ ថ្ងៃ បើសិនជាមិនមានភាគីណាមួយដាក់ពាក្យជំទាស់ជាលាយលក្ខណ៍អក្សរទៅរដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ តាមរយៈលេខាធិការដ្ឋាននៃក្រុមប្រឹក្សាអាជ្ញាកណ្តាល ក្នុងរយៈពេលនេះទេ។*

**ហត្ថលេខារបស់សមាជិកក្រុមអាជ្ញាកណ្តាល**

**អាជ្ញាកណ្តាលជ្រើសរើសដោយភាគីនិយោជក ៖**

ឈ្មោះ ៖ **អ៊ុំ សុទ្ធី**

ហត្ថលេខា ៖ ------------------------------

**អាជ្ញាកណ្តាលជ្រើសរើសដោយភាគីកម្មករនិយោជិត ៖**

ឈ្មោះ ៖ **លឹម សុវណ្ណា**

ហត្ថលេខា ៖------------------------------

**ប្រធានក្រុមអាជ្ញាកណ្តាល ៖**

ឈ្មោះ ៖ **ម៉ែន ម៉ុនឈា**

ហត្ថលេខា ៖ ------------------------------

ក្រុមប្រឹក្សាអាជ្ញាកណ្តាល THE ARBITRATION COUNCIL